# សម្តេចក្រឡាហោម ស ខេង

## ការធ្វើទេសន្តរប្រវេសន៍របស់ប្រជាពលរដ្ឋមួយចំនួនធំបានទទួលនូវការងារ ប្រាក់ចំណូលសម្រាប់ជីវភាពគ្រួសារ និងសង្គមជាតិ ប៉ុន្តែវាក៏មានផលប៉ះពាល់ដល់សង្គមជាតិផងដែរ ក្នុងចំណោមអ្នកធ្វើទេសន្តរប្រវេសន៍ដែលមានប្រមាណជាងមួយលាននាក់

(បន្ទាយមានជ័យ)៖នាព្រឹកថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១៦ នៅសាលាខេត្តបន្ទាយមានជ័យ មានបើកកិច្ចប្រជុំអន្តរក្រសួង ស្តីពីការ ដកពិសោធន៍លើការងារគ្រប់គ្រង លំហូរមិនប្រក្រតី នៃពលករឆ្លងកាត់ព្រំដែន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ដោយមានការអញ្ជើញចូលរួមក្នុងពី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន និងស្ថានកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ ប្រទេសថៃ និងខេត្តទាំងប្រាំពីរ ជាប់ព្រំដែនថៃចូលរួមផងដែរ។



**សម្តេចក្រឡាហោម ស ខេង** បានមានប្រសាសន៍ថា៖ **ការធ្វើទេសន្តរប្រវេសន៍របស់ប្រជាពលរដ្ឋមួយចំនួនធំបានទទួលនូវការងារ ប្រាក់ចំណូលសម្រាប់ជីវភាពគ្រួសារ និងសង្គមជាតិ។ ប៉ុន្តែវាក៏មានផលប៉ះពាល់ដល់សង្គមជាតិផងដែរក្នុងចំណោមអ្នកធ្វើទេសន្តរប្រវេសន៍ដែលមានប្រមាណជាងមួយលាននាក់ និងកំពុងតែបន្តកើនឡើងរៀងរាល់ថ្ងៃ បាននាំមកនូវបញ្ហាប្រឈមជាច្រើនដូចជា៖ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការរងទារុណកម្ម និងការជួញដូរមនុស្សជាដើម ដែលបញ្ហាទាំងនេះក្លាយជាបន្ទុកដ៏ធ្ងន់ធ្ងរដល់គ្រួសារ សង្គម និងរាជរដ្ឋាភិបាល។**



រាជរដ្ឋាភិបាល បានផ្តល់ជម្រើសជូនប្រជាពលរដ្ឋក្នុងការស្វែងរកការងារធ្វើ ទទួលបានប្រាក់ចំណូលល្អ ថែមទាំងចូលរួមបង្កលក្ខណៈសម្បត្តិគ្រប់បែបយ៉ាង តែប្រជាពលរដ្ឋមួយចំនួនធំបាន និងកំពុងស្វែងរកច្រកចេញទៅធ្វើការងារនៅក្រៅប្រទេសដោយប្រថុយប្រថាន និងគួបផ្សំកង្វះខាតនូវវិធានការគ្រប់គ្រង និងបទដ្ឋានឯកភាពជាប្រព័ន្ធផងនោះ បានធ្វើឲ្យកើតមាននូវភាពអនាធិបតេយ្យក្នុងការឆ្លងកាត់ព្រំដែនខុសនីតិវិធី។

**សម្តេចក្រឡាហោម** ក៏បានអំពាវនាវដល់បណ្តាអ្នកពាក់ព័ន្ធក្នុងបញ្ហានេះជួយពិចារណា និងផ្តល់មតិយោបល់សមស្របទាំងវិធានការចំពោះមុខ និងវិធានការយុទ្ធសាស្ត្រយូរអង្វែង និងដាក់ចេញនូវវិធានការថ្មីៗដើម្បីអនុវត្តទាំងអស់គ្នា។ **ហើយសូមឲ្យបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ បង្ហាញពីការទទួលខុសត្រូវតាមតួនាទី ភារកិច្ច និងភាពប្រឈមនានារបស់ខ្លួន។**

គួរបញ្ជាក់ផងដែរថា ខេត្តដែលជាប់ព្រំដែន កម្ពុជា ថៃ រួមមាន៖ បាត់ដំបង បន្ទាយមានជ័យ ព្រះវិហារ ឧត្តមានជ័យ ប៉ៃលិន កោះកុង និងពោធិសាត់ និងមានច្រកទ្វារអន្តរជាតិ០៥, ច្រកតំបន់១២ និងច្រករបៀង ៤៣ សរុបចំនួន៦០។ ប្រជាពលរដ្ឋដែលឆ្លងកាត់ព្រំដែន ឬច្រកទ្វារទាំងនោះត្រូវបានផ្តល់ឯកសារឆ្លងកាត់

ចំនួន ០៥ប្រភេទ៖ លិខិតឆ្លងដែន លិខិតធ្វើដំណើរ ប័ណ្ណព្រំដែន សំបុត្រឆ្លងដែន និងប័ណ្ណស៊ីជម្ពូ។





## សម្តេចក្រឡាហោម ស ខេង៖ អ្វីដែលជាកាតព្វកិច្ចរបស់យើងត្រូវធ្វើឲ្យអស់ដូចជាការអប់រំផ្សព្វផ្សាយប្រជាពលរដ្ឋ ការចាប់មេខ្យល់ មកផ្តន្ទាទោស

(បន្ទាយមានជ័យ)នាព្រឹកថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ នៅសាលាខេត្តបន្ទាយមានជ័យ **សម្តេចក្រឡាហោម** បានមានប្រសាសន៍សរុបមតិយោលបល់ និង ផ្តល់អនុសាសន៍ សម្រាប់ជាដំណោះស្រាយចំពោះបញ្ហាលំហូរមិនប្រក្រតី នៃពលករឆ្លងកាត់ព្រំដែននេះ ដែលមានខ្លឹមសារដូចខាងក្រោម៖ ការពិតហើយយើងធ្វើអ្វីមួយក៏ដោយ យើងពឹងទៅលើកត្តាអត្តនោម័តរបស់យើង ការខិតខំប្រឹងប្រែងរបស់ យើង ប៉ុន្តែទាក់ទងនឹងបញ្ហានេះ គឺ ប្រហែលជាមិនអាចជៀសផុតពីការពឹងផ្អែកការចូលរួមសហប្រតិបត្តិការពី ភាគីថៃទេ បើសិនគ្មានការចូលរួមសហប្រតិបត្តិការរឹងមាំពីភាគីថៃ ធ្វើដូចម្តេចក៏មិនចេញដែរ។



ខ្ញុំចង់ឲ្យយើងរួមគ្នាពិចារណា ខ្ញុំនឹងដឹកនាំប្រជុំខេត្តជាប់ព្រំដែនប្រហែលនៅចុងឆ្នាំនេះ យើងនឹងដាក់បញ្ហានេះ បន្ទាប់ពីជជែកពិភាក្សាជាមួយក្រសួងពាក់ព័ន្ធដូចជា ក្រសួងការងារ ក្រសួងការបរទេស ក្រសួងមហាផ្ទៃបើស្រុះស្រួល គ្នាយើងនឹងអាចលើកបញ្ហានេះ ដែលមាន ២ ចំណុចគឺ៖

**ទី១- ស្នើថៃកុំឲ្យប្តូរផ្លាស់លឿនពេក ដើម្បីសម្របច្បាប់ឲ្យពលករកំពុងស្នាក់នៅខុសច្បាប់ ។**

**ទី២- ជួយទប់ស្កាត់លំហូរចូលថ្មី កាលណាឃើញពលករថ្មីទៅសូមកុំទទួល ( ឲ្យក្រុមហ៊ុននានាកុំទទួល យកពលករថ្មី) ។**

**សម្តេចក្រឡាហោម** បានផ្តល់អនុសាសន៍ដ៏មានសារៈសំខាន់ដល់ស្ថាប័ន ក្រសួងពាក់ព័ន្ធ **“អ្វីដែលជាកាតព្វកិច្ចរបស់យើងត្រូវធ្វើឲ្យអស់ ដូចជាការអប់រំផ្សព្វផ្សាយប្រជាពលរដ្ឋ ការចាប់មេខ្យល់ មកផ្តន្ទាទោស”** ។ល។ ហើយរបៀងត្រូវបិទឲ្យអស់ភារកិច្ចរបស់យើងទាំងខាងកងទ័ព និងខាងនគរបាល គឺត្រូវបិទច្រករបៀងឲ្យបានកុំគប់គិត ជាមួយអ្នករត់ពន្ធមនុស្សឲ្យសោះ។

**សម្តេចក្រឡាហោម** មានប្រសាសន៍ថ្លែងអំណរគុណ និងកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់តួអង្គពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ទោះបីជាលទ្ធផលមិនទាន់បានជាទីពេញចិត្ត ប៉ុន្តែយើងបានទទួលការវាយតម្លៃ លេខ២ ពីសហរដ្ឋអាមេរិក ដែលនេះជាជោគជ័យរបស់យើង។

**សម្តេចក្រឡាហោម បានធ្វើការកត់សម្គាល់ចំនួន ៣ ចំណុច ដូចខាងក្រោម៖**

**ទី១- ទាក់ទងនឹងពលករកម្ពុជាកំពុងធ្វើការនៅប្រទេសថៃ** ដែលអង្គប្រជុំនិយាយពីលំហូរចូលមិនប្រ ក្រតី នេះបានន័យថា គ.ជ.ប.ជ ទទួលខុសត្រូវរួមទាំងអស់។ **ឯកឧត្តម នាយឧត្តមសេនីយ៍ ម៉ៅ ច័ន្ទតារា** បានលើកឡើងហើយ អំពីការខិតខំប្រឹងប្រែងរបស់យើងក្នុងការដោះស្រាយឯកសារផ្លូវច្បាប់ ដើម្បីសម្របសម្រួលច្បាប់ដល់ពលករធ្វើការខុសច្បាប់នៅថៃ។ ដូច្នេះ សូមឲ្យក្រុមការងារដឹកនាំដោយ **ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួង ការងារ** ត្រូវខិតខំប្រឹងប្រែងទំនាក់ទំនងជាមួយថៃបន្តទៀត ដើម្បីធ្វើឲ្យប្រាកដប្រជាទាក់ទងនឹងគោលការណ៍ និងវិធានការទាំងឡាយដើម្បី ឈានទៅដោះស្រាយបញ្ហានេះឲ្យបានឆាប់ជាង។

**ទី២- ទាក់ទងនឹងការទប់ស្កាត់លំហូរចូលថ្មី** ដែលបញ្ហាដូចដែលបទអន្តរាគមន៍នានាបានលើកឡើង ពិសេស **ឯកឧត្តម ច័ន្ទ សុផល** បានលើកឡើងពីការអប់រំប្រជាពលរដ្ឋ និងការទប់ស្កាត់ចំពោះការជ្រើសរើសពលករដែលមិនស្របច្បាប់មានហានិភ័យខ្ពស់ អាចឈានទៅដល់ការជួញដូរមនុស្ស។ ទន្ទឹមនេះ យើងត្រូវផ្តោតលើ ២ ចំណុចគឺ៖

-ការខិតខំការទាក់ទាញវិនិយោគ ដើម្បីបង្កើតការងារបានច្រើន និងរៀបចំល័ក្ខខ័ណ្ឌការងារសម្រាប់ ប្រជាពលរដ្ឋ ដើម្បីទាក់ទាញកុំឲ្យពួកគាត់ទៅរកការងារនៅបរទេស។

-ការបណ្តុះបណ្តាលវិជ្ជាជីវៈ មានសារសំខាន់ណាស់បើគាត់មានជំនាញគាត់អាចទទួលបានប្រាក់កម្រៃច្រើន តែបើមិនមានជំនាញទេ ទៅធ្វើការក្រៅប្រទេស ក៏បានកម្រៃប្រហែលក្នុងស្រុកដែរ។

ឆ្លើយតបនឹង **ឯកឧត្តម សួន បវរ** ដែលបានលើកឡើងទាក់ទងនឹងការសុំបើកច្រកបន្ថែម ដែលហៅថា **របៀងគឺត្រូវតែបិទ** ប៉ុន្តែការបើកច្រកបន្ថែម យើងត្រូវពិនិត្យតាមការចាំបាច់ក្នុងការបើកច្រកសម្រាប់ការចេញចូល ឧទាហរណ៍ប្រជាពលរដ្ឋនៅឆ្ងាយពីច្រកនោះ គាត់មិនអាចចេញចូលព្រឹកល្ងាចបានទេ ដូច្នេះត្រូវរៀបចំ និងសូមបញ្ជូនសំណើមក យើងនឹងពិភាក្សាជាមួយក្រសួងការបរទេស ដើម្បីចរចាជាមួយភាគីថៃ ព្រោះត្រូវមានការព្រមព្រៀង ពីភាគីថៃ។ **"សូមឲ្យយល់ថា ដែលហៅថារបៀងគឺបិទ"** ព្រោះយើងមានច្រកហើយ យើងបើកច្រកឲ្យច្រើនទៅ សម្រាប់ការចេញចូលព្រឹកល្ងាចរបស់ប្រជាពលរដ្ឋ ជៀសវាងលួចចេញចូលតាមច្រករបៀង ។

**ទី៣- ទាក់ទងនឹងការត្រៀមជួយសង្គ្រោះពេលដែលពលកររងគ្រោះ** ដោយការបញ្ជូនត្រឡប់មកវិញ ឬរត់គេចខ្លួន ឬរងគ្រោះគ្រប់បែបយ៉ាងតាមរយៈការប្រើប្រាស់កម្លាំងពលកម្ម គឺយើងត្រៀមដូចដែលយើងធ្លាប់បានធ្វើកន្លងមក ហើយយើងនឹងបន្តធ្វើទៀត ។





